**ខ្លឹមសារសង្ខេបសាលដីកាព្រហ្មទណ្ឌលេខ១១៩(២០១៣) របួសដោយចេតនានិងជេរប្រមាថ**

**ពាក្យគន្លឹះ៖** របួសដោយចេតនា, សាក្សីពាក់ព័ន្ធ, កម្រិតភស្តុតាង,សំអាងហេតុ

**អង្គហេតុនិងសេចក្តីសម្រេច៖** អង្គហេតុ ត្រូវបានសង្ខេបរួចហើយក្នុងអត្ថបទសង្ខេបសាលក្រមលេខ២០៩(២០១១) និងសាលដីកាលេខ២៥ក្រ(២០១២)។ ជនជាប់ចោទឈ្មោះ **ស.រ.ណ** បានកើតទុក្ខមិនសុខចិត្តនឹងសាលដីកាសាលាឧទ្ធរណ៍ និងក្នុងឆ្នាំ២០១២ ដដែល បានប្តឹងប្រឆាំងនឹងសាលដីកាទាំងមូល។ ក្នុងនីតិវិធីតុលាការកំពូល គាត់បានលើកអំពីសាក្សីថ្មីពីររូប ព្រមទាំងរូបថតបង្ហាញថា គាត់ត្រូវបានគេវាយ។

តំណាងមហាអយ្យការតុលាការកំពូល បានស្នើតម្កល់សាលដីកាសាលាឧទ្ធរណ៍លេខ២៥ក្រ ទុកជាបានការ។ តុលាការកំពូល បានអះអាងថា សាក្សីថ្មីដែលបង្ហាញនោះគឺពាក់ព័ន្ធនឹងជម្លោះរវាង ស.រ.ណ. នឹងប្តីរបស់ជនរងគ្រោះ ស.ផ ដែលក្នុងរឿងនេះ គឺជនរងគ្រោះ ស. ផ (ស្ត្រី) បានចោទគាត់ថាជាអ្នកវាយ។ តុលាការកំពូល បានអះអាងថា ចម្លើយ(នៃជនរងគ្រោះ) តែមួយមុខមិនអាចចាត់ទុកជាភស្តុតាងដាក់បន្ទុកបានឡើយ៖

*...ករណីនេះឃើញថា ភស្តុតាងទាំងនេះមានលក្ខណៈស៊ីសង្វាក់គ្នានិងមានតម្លៃជាភស្តុតាងដាក់បន្ទុកហួសពីវិមតិសង្ស័យ ដែលអាចកំណត់បាននូវអត្ថិភាពនៃបទល្មើសបង្ករបួសដោយចេនា ដូចជា ការប្រកាសទោសរបស់តុលាការអង្គហេតុហើយ។*

*- យល់ឃើញថា ការដែលតុលាការអង្គហេតុ សម្រេចប្រកាសទោសលើជនជាប់ចោទពីបទល្មើសជេរប្រមាថជាសាធារណៈតាមមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌនៅតុលាការអង្គហេតុ មិនទាន់បានបង្ហាញអំពីសំអាងហេតុដាក់បន្ទុកណាមួយទាក់ទិននឹងសកម្មភាពជេរប្រមាថទេ ក្រៅតែពីសំអាងតែទៅលើចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ស.ផ** ដែលអះអាងនាពេលទំនាស់នោះ ជនជាប់ចោទបានជេរខ្លួនដោយប្រើពាក្យ ថោក តែប៉ុណ្ណោះ។ ចម្លើយនេះមិនអាចចាត់ទុកជាភស្តុតាងដាក់បន្ទុកបានឡើយ។ ឯការដែលតុលាការអង្គហេតុ សំអាងហេតុសម្រេចបង្គាប់ឲ្យជនជាប់ចោទឈ្មោះ **ស.រ.ណ.** សងថ្លៃព្យាបាលរបួស និងជម្ងឺចិត្តចំនួន៤លានរៀលឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីនោះ ក៏ពុំទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយដែរ ព្រោះថាមិនទាន់បង្ហាញអំពីសំអាងហេតុនៃទំហំខូចខាតកំរិតណានោះទេ។ ករណីនេះបង្ហាញថាការធ្វើសំអាងហេតុមិនគ្រប់គ្រាន់ ដែលចាត់ទុកថាមិនមានសំអាងហេតុ។ ដូច្នេះតាមស្មារតីមាត្រា៤១៩ ចំណុចទី៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ ម្ចាស់បណ្តឹងសាទុក្ខមានមូលហេតុនៃបណ្តឹងសាទុក្ខរបស់ខ្លួនហើយ។*

ឈរមូលដ្ឋាននេះចៅក្រមកំពូលបានសម្រេចតម្កល់ផ្នែកខ្លះ និង បដិសេធផ្នែកខ្លះហើយបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះឡើងវិញចំណុចដែលមិនមានភាពច្បាស់លាស់។

**កំណត់សំគាល់៖ ១.** ទោះបីជាក្រមព្រហ្មទណ្ឌមិនបាននិយាយដល់កម្រិតភស្តុតាង ហួសពីវិមតិសង្ស័យ តុលាការកំពូលទទួលស្គាល់កម្រិតភស្តុតាងនេះ។ **២.** ពាក់ព័ន្ធនឹងកម្រិតភស្តុតាងនេះ ភស្តុតាងជាពិសេសភស្តុតាងដាក់បន្ទុកត្រូវច្រើន ចម្លើយតែមួយមុខរបស់ជនរងគ្រោះមិនគ្រប់គ្រាន់ទេ។ **៣.** ភស្តុតាងថ្មី ដាក់មក ត្រូវតែពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់។ **៤.** កង្វះសំអាងហេតុ មានន័យថាគ្មានសំអាងហេតុ។ ក្នុងសាលក្រមក៏ដូចជាសាលដីកា ច្បាប់តម្រូវឲ្យមានសំអាងហេតុគ្រប់គ្រាន់នឹងច្បាស់លាស់ដើម្បីឲ្យភាគីងាយស្រួលក្នុងការសម្រេចប្តឹងឧទ្ធរណ៍ឬមិន (សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ)។ **៥.** មកដល់ថ្ងៃសាលដីកា (ឧសភា ឆ្នាំ២០១៣) មានរយៈពេលប្រហែល៤ឆ្នាំ។ សំណុំរឿងនេះមិនទាន់ចប់សព្វគ្រប់ជាស្ថាពរទេ។ សូមចុចលើតំណភ្ជាប់នេះ៖ សាលក្រមលេខ០៩ និង សាលដីកាលេខ២៥។

**Summary of Supreme Court Judgment No. 119 (2013)**

**Keywords**: Intentional violence, relevant witnesses, standard of evidence, reasoning of facts and decisions.

**Procedural History and Decision**: The facts were previously summarized in Judgment No. 09 (2011) and Appeal Decision No. 25 Kr (2012). The accused, S.R.N., dissatisfied with the Appeal Court ruling, filed a cassation appeal in 2012 against the entire decision.

During the Supreme Court proceedings, the accused introduced two new witnesses and photographs alleging that he was the one who was beaten. The prosecution representative requested to uphold the Appeal Court's decision.

The Supreme Court noted that the new witnesses presented were related to a dispute between the accused (S.R.N.) and the victim's husband.

*Regarding the intentional violence charge, the court found that existing evidence was consistent and met the burden of proof "beyond a reasonable doubt" which shows existence of intentional injury as the court of first instance pronounced.*

*The Court found the lower court's conviction for "Public Insult" based on article 307 lacked sufficient reasoning and the court did not show incriminating evidence except basing solely on the statement of the victim (S.P.), who claimed the accused called her "cheap" (thork). A victim's statement alone cannot be considered sufficient incriminating evidence. The Court challenged the order for the accused to pay 4 million Riel for medical treatment and mental damages. The court found there was insufficient basis/reasoning to justify this amount. There was no clear evidence or reasoning regarding the specific scale of the damages; insufficient reasoning" is considered a "lack of reasoning". Pursuant to Article 419 (Point 8) of the Code of Criminal Procedure, complainant has ground to appeal.*

…. The Supreme Court decided to uphold parts of the previous decision and overturn other parts, remanding the case back to the Court of Appeal for retrial on the points that lacked clarity.

**Notes: 1**. Although the Criminal Code does not explicitly mention "beyond a reasonable doubt," the Supreme Court recognizes and applies this standard. **2.** Incriminating evidence must be substantial; a victim's testimony alone is insufficient for a conviction. **3.** New evidence

submitted must be directly relevant to the specific charges. **4**. Courts are legally required to provide clear and sufficient reasoning in their judgments so parties can understand the basis for the decision and decide whether to appeal, and **5.** As of the date of this judgment (May 2013), the case had lasted approximately four years and was still not fully resolved.